**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**
**លេខៈ ១៦ សសរ ក.ស.វ.**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## ទេសរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៩ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៨/១៣៩៣ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យលេខ៤៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានឃើញសេចក្តីសម្រេចលេខ០៣ សសរ ក.ស.វ. ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សម្រេច

**ប្រការ១**: ត្រូវបានបង្កើតគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ណុលឡា** | ប្រធាន ក.ស.វ. | ប្រធាន |
| ២. ឯកឧត្តម **យឹម ណុលសន** | អនុប្រធានប្រចាំការ ក.ស.វ. | សមាជិក |
| ៣. ឯកឧត្តម **នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត** | អនុប្រធាន ក.ស.វ. | សមាជិក |
| ៤. ឯកឧត្តម **លី គឹមសុខ** | អនុប្រធាន ក.ស.វ. | សមាជិក |



Office of the Council of Ministers
Economic, Social and Cultural Council (ECOSOCC)
Address: #41, Russian Federation Blvd.
ទូរស័ព្ទ/ទូរសារ : (៨៥៥)-២៣ ២១ ១៩ ៤៣ , Tel/Fax : (855)-23 21 19 43

៥. ឯកឧត្តម **អ៊ីវ ចុង** អនុប្រធាន ក.ស.វ. សមាជិក

៦. ឯកឧត្តម **ឆយ អូន** អនុប្រធាន ក.ស.វ. សមាជិក

៧.ឯកឧត្តម **អ៊ុន វ៉ាល់ឡឺ** អគ្គលេខាធិការ ក.ស.វ. សមាជិកអចិន្ត្រៃយ៍

**ប្រការ២**: គណៈប្រតិបត្តិនេះមានភារកិច្ចដូចតទៅ៖

១. ពិនិត្យនិងផ្តល់យោបល់លើរាល់ការងារពិសេសនិងចាំបាច់របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌តាមការកំណត់ដោយប្រធានក.ស.វ.។

២. ពិនិត្យនិងវាយតម្លៃការស្នើសុំតម្លើងថ្នាក់និងឋានន្តរស័ក្តិ ការលើកទឹកចិត្ត ការតែងតាំង និងការសម្រេចផ្សេងៗទៀត ចំពោះសមាជិក សមាជិកាក.ស.វ. និងមន្ត្រីក្រោមឱវាទនៃអគ្គលេខាធិការដ្ឋានក.ស.វ.។

**ប្រការ៣**: ១. ក្នុងកិច្ចប្រជុំពាក់ព័ន្ធនឹងការវាយតម្លៃដែលមានចែងក្នុងប្រការ២ ចំណុច២ អាចអញ្ជើញសមាជិក សមាជិកា ២រូបជាតំណាងក.ស.វ. ចូលរួមប្រជុំក្នុងករណីពាក់ព័ន្ធនឹងសមាជិក សមាជិកាក.ស.វ. និងមន្ត្រី ២រូបជាតំណាងអគ្គលេខាធិការដ្ឋានក.ស.វ. ចូលរួមប្រជុំក្នុងករណីពាក់ព័ន្ធនឹងមន្ត្រីអគ្គលេខាធិការដ្ឋានក.ស.វ.។

២. តំណាងក.ស.វ.និងតំណាងអគ្គលេខាធិការដ្ឋានមានសិទ្ធិផ្តល់យោបល់ប៉ុន្តែពុំមានសិទ្ធិសម្រេចឡើយ។

**ប្រការ៤**: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥**: អនុប្រធានប្រចាំការ អនុប្រធាន សមាជិក សមាជិកានៃក.ស.វ. អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក អនុប្រធានផ្នែក មន្ត្រីនៃអគ្គលេខាធិការដ្ឋានក.ស.វ. និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៣រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩

**ទេសរដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**យឹម ឈុលឡា**

***កន្លែងទទួល:***

*- ទីស្តីការគណៈរដ្ឋមន្ត្រី*

*- អគ្គលេខាធិការដ្ឋាន ក.ស.វ.*

*- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*

*- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានក.ស.វ.*

*- ដូចប្រការ ៥ "**ដើម្បីអនុវត្ត**"*

*- រាជកិច្ច*

*- ឯកសារ-កាលប្បវត្តិ*